**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៥៧១ សហវ.ប្រក

រាជធានីភ្នំពេញ ថ្ងៃទី ១៩ ខែ សីហា ឆ្នាំ ២០១០

# ប្រកាស
## ស្តីពី
## នីតិវិធីនៃការបង់ពន្ធ និងអាករ លើទំនិញនាំចេញ និងទំនិញនាំចូល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/១៨ចុះថ្ងៃទី២៤ខែមករាឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៧/០១៧ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីគយ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករាឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៣៤ អនក្រ.បក ចុះថ្ងៃទី ១៥ ខែ កញ្ញាឆ្នាំ ២០០៨ ស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ នាយកដ្ឋានពន្ធដារ និងរតនាគារជាតិនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុឱ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ និងអគ្គនាយកដ្ឋានរតនាគារជាតិ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១៩២ អនក្រ.បក ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីការបង្កើតនាយកដ្ឋានរដ្ឋាករ នាយកដ្ឋានរបបគយ និងនាយកដ្ឋានគ្រប់គ្រងតំបន់រួចពន្ធ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- យោងតាមសំណូមពរការងារចាំបាច់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

**ប្រការ ១ .-**

ទំនិញនាំចូល ឬទំនិញនាំចេញទាំងឡាយ ពុំអាចយកចេញពីការិយាល័យគយ សន្និធិគយបណ្តោះអាសន្ន ឬកណ្តាគារគយមានដែនកំណត់បានទេ មុនពេលដែល ពន្ធ អាករ កម្រៃផ្សេងៗ ប្រាក់ពិន័យ ការប្រាក់ និងបន្ទុកនានាត្រូវបានទូទាត់ ឬមានការធានាដោយនិមុត្តិធានាដែលមានការឯកភាពពីរដ្ឋបាលគយ ។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA
www.mef.gov.kh
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798
mef_adm@yahoo.com

ទំនិញពុំអាចត្រូវបានយកចេញពីទីកន្លែង ដូចមានចែងក្នុងបញ្ញត្តិកថាខណ្ឌទីមួយនៃប្រការនេះ ដោយគ្មានការអនុញ្ញាតពីរដ្ឋបាលគយ ។

បន្ទាប់ពីទទួលបានការអនុញ្ញាតពីរដ្ឋបាលគយ ទំនិញត្រូវបានយកចេញជាបន្ទាន់ពីទីកន្លែងដូចមានចែងក្នុងបញ្ញត្តិកថាខណ្ឌទីមួយនៃប្រការនេះ ។

**ប្រការ ២ .-**

ពន្ធ អាករ កម្រៃផ្សេងៗ និងបន្ទុកនានាត្រូវបានគណនាលើប្រតិវេទន៍គយ ដែលត្រូវបានផ្ទៀងផ្ទាត់រួចដោយមន្ត្រីគយ ។

**ប្រការ ៣ .-**

ពន្ធ អាករ កម្រៃផ្សេងៗ និងបន្ទុកនានាដែលត្រូវបង់សម្រាប់មុខទំនិញនីមួយៗ ក្នុងប្រតិវេទន៍គយតែមួយ ត្រូវគិតជាប្រាក់រៀលដោយតម្លើងដល់ខ្ទង់រយជិតបំផុត ។

**ប្រការ ៤ .-**

ការបង់ពន្ធ អាករ កម្រៃផ្សេងៗ និងបន្ទុកនានាត្រូវធ្វើនៅតាមការិយាល័យគយមានសមត្ថកិច្ចក្នុងពេលម៉ោងធ្វើការ បន្ទាប់ពីការចុះបញ្ជិកាប្រតិវេទន៍គយដោយមន្ត្រីគយ និងនៅមុនពេលត្រួតពិនិត្យរូបវន្តលើទំនិញ ក្នុងករណីចាំបាច់ ។

ការបង់ប្រាក់នេះអាចធ្វើឡើងក្រោយពេលត្រួតពិនិត្យរូបវន្តលើទំនិញ ប្រសិនបើមានការអនុញ្ញាតដោយឡែកពីអគ្គនាយកគយ និងរដ្ឋាករកម្ពុជា ។

**ប្រការ ៥ .-**

អ្នកនាំចេញ អ្នកនាំចូល ឬម្ចាស់ទំនិញ ត្រូវទទួលខុសត្រូវចំពោះ ពន្ធ អាករ កម្រៃផ្សេងៗ និងបន្ទុកនានា លើទំនិញនាំចេញ និងទំនិញនាំចូល ។

ក្នុងករណីដែល អ្នកនាំចេញ អ្នកនាំចូល ឬម្ចាស់ទំនិញមិនត្រូវបានរកឃើញ ភ្នាក់ងារជើងសារគយត្រូវទទួលខុសត្រូវចំពោះ ពន្ធ អាករ កម្រៃផ្សេងៗ និងបន្ទុកនានាលើទំនិញនាំចេញ និងទំនិញនាំចូល ។

ក្នុងករណីសន្និធិគយបណ្តោះអាសន្ន ឬកណ្តាគារគយមានដែនកំណត់ប្រតិបត្តិករនៃសន្និធិ និងកណ្តាគារទាំងនេះ ជាអ្នកទទួលខុសត្រូវចំពោះ ពន្ធ អាករ កម្រៃផ្សេងៗ និងបន្ទុកនានា ដោយមិនទាន់គិតដល់ទោសទណ្ឌផ្សេងទៀតដែលអាចត្រូវទទួល រហូតដល់ទំនិញត្រូវបាននាំចេញទៅវិញ នាំចូលបណ្តោះអាសន្ន នាំចូលដើម្បីប្រើប្រាស់ក្នុងប្រទេស បង្វែរទៅទីកន្លែងសន្និធិ ឬកណ្តាគារផ្សេងទៀត ឬបំផ្លាញចោល ដោយមានការអនុញ្ញាតពីរដ្ឋបាលគយ ។



la

នៅក្នុងករណីមាត្រា ២៦ និងមាត្រា ២៧ នៃច្បាប់ស្តីពីគយ ប្រសិនបើលក្ខខណ្ឌនៃការលើកលែងពន្ធ និងអាករ មិនត្រូវបានបំពេញសព្វគ្រប់ ការទទួលខុសត្រូវចំពោះពន្ធ និងអាករ ជាបន្ទុករបស់បុគ្គលដែលបានទទួលការលើកលែងពន្ធ និងអាករ ។ ប្រសិនជាមិនអាចរកឃើញបុគ្គលនោះ បន្ទុកនេះត្រូវធ្លាក់លើបុគ្គលដែលកាន់កាប់ទំនិញទាំងនេះ ។

ជនណាដែលជាអ្នកកាន់កាប់ទំនិញនាំចូល នាពេលដែលមធ្យោបាយដឹកជញ្ជូនចូលក្នុងដែនគយ រាប់បញ្ចូលទាំងប្រតិបត្តិករមធ្យាយបាយដឹកជញ្ជូនផង ជននោះជាអ្នកទទួលខុសត្រូវលើពន្ធ អាករ នាំចូលនៃទំនិញនោះ ។

**ប្រការ ៦ .-**

ពន្ធ អាករ កម្រៃផ្សេងៗ ពិន័យ និងបន្ទុកនានាត្រូវបានបង់ជាប្រាក់រៀលក្នុងទម្រង់ជាសាច់ប្រាក់ មូលប្បទានប័ត្រ ឬទម្រង់ផ្សេងទៀតនៃលិខិតុបករណ៍ហិរញ្ញវត្ថុដែលទទួលស្គាល់ និងអនុញ្ញាតដាក់ឲ្យប្រើប្រាស់ដោយធនាគារជាតិនៃកម្ពុជា ។

ការបង់អាចត្រូវបានធ្វើដោយការផ្ទេរមូលនិធិតាមប្រព័ន្ធអេឡិកត្រូនិច ស្របតាមលក្ខខណ្ឌ និងនីតិវិធីនានាដែលអាចកំណត់ដោយរដ្ឋបាលគយ និងធនាគារជាតិនៃកម្ពុជា ។

**ប្រការ ៧ .-**

រដ្ឋបាលគយ ត្រូវទទួលស្គាល់បង្កាន់ដៃផ្ទេរការដែលចេញដោយធនាគារជាតិ នៃកម្ពុជា ស្របតាមបញ្ញត្តិប្រការ ៦ ខាងលើ ដោយចាត់ទុកជា ទឡ្ហីករណ៍ នៃការបង់ពន្ធ អាករ កម្រៃផ្សេងៗ និងបន្ទុកនានា ។

**ប្រការ ៨ .-**

រដ្ឋបាលគយត្រូវចេញបង្កាន់ដៃផ្ទេរការសម្រាប់រាល់ការទទួលប្រាក់ដែលបានបង់ទាំងអស់ ។

**ប្រការ ៩ .-**

រដ្ឋបាលគយអាចអនុញ្ញាតឲ្យយកទំនិញពីគយ មុនពេលបង់ពន្ធ អាករ កម្រៃផ្សេងៗ និងបន្ទុកនានា ប្រសិនបើមានការតម្កល់ការធានា ជាសាច់ប្រាក់ ឬជានិមុត្តិធានា ស្របតាមបញ្ញត្តិប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីនិមុត្តិធានាជាធរមាន ។

បុគ្គលដែលមានបំណងទទួលនូវគុណប្រយោជន៍ពីនីតិវិធីនេះ ត្រូវស្នើសុំជាលាយលក្ខណ៍អក្សរទៅរដ្ឋបាលគយ ដោយភ្ជាប់ជាមួយនូវនិមុត្តិធានា ។ បុគ្គលដែលមានបំណងប្រើប្រាស់និមុត្តិធានារយៈពេលវែង សម្រាប់ការប្រើប្រាស់ច្រើនដងជាបន្តបន្ទាប់ត្រូវតម្កល់និមុត្តិធានា គ្រប់គ្រាន់ ដែលអាចធានាបាននូវ ពន្ធ អាករ កម្រៃផ្សេងៗ និងបន្ទុកនានាដែល

អាចកើតមានឡើង ។ និមុត្តិជានាទាំងនេះ ត្រូវគ្រប់គ្រងឃ្លាំមើលដោយរដ្ឋបាលគយ ដើម្បីជានាថា ពន្ធ អាករ កម្រៃផ្សេងៗ ការប្រាក់ និងបន្ទុកនានា នឹងមិនលើសពីតម្លៃនិមុត្តិជានាឡើយ ។

ការទូទាត់ទាំងស្រុងនូវទឹកប្រាក់ដែលត្រូវបង់ត្រូវធ្វើឡើងក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃអនុញ្ញាតឱ្យយកទំនិញចេញពីគយ ។ ការខកខានទូទាត់ដូចនេះ នឹងត្រូវរងនូវវិធានការគយក្នុងការប្រមូលបំណុល ស្របតាមបញ្ញត្តិមាត្រា ៣៨ មាត្រា ៣៩ និងមាត្រា ៤០ នៃច្បាប់ស្តីពីគយ ។

**ប្រការ ១០ .-**

ក្នុងករណីមានវិវាទ ឬការតវ៉ាពាក់ព័ន្ធនឹងចំនួនទឹកប្រាក់ពន្ធ អាករ កម្រៃផ្សេងៗ និងបន្ទុកនានាដែលត្រូវបង់ អ្នកនាំចេញ អ្នកនាំចូល ម្ចាស់ទំនិញ ឬតំណាងរបស់ខ្លួនអាចត្រូវបានអនុញ្ញាតឲ្យយកទំនិញចេញពីគយ ក្រោយពីបានតម្កល់ប្រាក់ជានា ឬនិមុត្តិជានាដែលមានការយល់ព្រមពីរដ្ឋបាលគយស្របតាមបទប្បញ្ញត្តិជាធរមាន ក្នុងពេលរង់ចាំការសម្រេចជាផ្លូវការលើការតវ៉ា ឬវិវាទនេះ ។

**ប្រការ ១១ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ១២ .-**

ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកគយ និងរដ្ឋាករកម្ពុជា អគ្គលេខាធិការ អគ្គនាយក នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ព្រមទាំងបុគ្គល និងស្ថាប័នពាក់ព័ន្ធផ្សេងទៀត ត្រូវអនុវត្តតាមខ្លឹមសារប្រកាសនេះ ឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន ៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
  " ដើម្បីជូនជ្រាប "
- ដូចប្រការ ១២
- រាជកិច្ច
- ឯកសារ - កាលប្បវត្តិ